060 888 966 - 077 811 168 (Telegram) info@construction-property.com

ព្រឹត្តិប័ត្រព័ត៌មាន ខ្មែរ:

Follow 94K



# ក្រុមហ៊ុនចិននឹងចាប់ផ្តើមស្លរមាសលើកដំបូងនៅមណ្ឌលគិរីឆាប់ៗនេះ ខណៈកំពុងពន្លឿនរៀបចំហេដ្ឋារចនាសម្ព័ន្ធ

៩ មេសា ២០២៣ ព័ត៌មានក្នុងស្រុក 2103 មើល




ក្រុនហ៊ុនចិនមួយទៀត គឺក្រុមហ៊ុន រង ឈីង អ៊ិនដាសស្ទ្រៀល អិនវេសមេន ខូអិលធីឌី (Rong Cheng Industrial Investment (Cambodia) Co., Ltd.) បាននិងកំពុងពន្លឿនរៀបចំហេដ្ឋារចនាសម្ព័ន្ធនៃចង្វាក់ផលិតកម្ម ក្នុងការរុករករ៉ែមាស ដើម្បីអាចឈានដល់ការចម្រាញ់រ៉ែមាសលើកដំបូងរបស់ខ្លួនឆាប់ៗនេះ ក្នុងខេត្តមណ្ឌលគិរី។

នេះបើយោងតាមការបញ្ជាក់របស់ ឯកឧត្តម ស៊ន សារុន អភិបាលរងខេត្តមណ្ឌលគិរី នៅថ្ងៃទី០៦ ខែមេសា ឆ្នាំ២០២៣។

ឯកឧត្តម បានលើកឡើងថា ក្រៅពីក្រុមហ៊ុន Renaissance Mineral Limited (Cambodia) របស់ប្រទេសអូស្ត្រាលី ក៏មានក្រុមហ៊ុនចិនមួយទៀតផងដែរ ដែលកំពុងរុករករ៉ែមាស នៅក្នុងភូមិសាស្ត្រ ឃុំចុងផ្លាស់ ស្រុកកែវសីមា ខេត្តមណ្ឌលគិរី។

ជាមួយគ្នានេះ លោក ទី សុផល ប្រធានមន្ទីររ៉ែ និងថាមពលខេត្តមណ្ឌលគិរី បានគូសបញ្ជាក់ថា ក្រុមហ៊ុនចិន ដែលទទួលបានច្បាប់អនុញ្ញាតធ្វើអាជីវកម្មរុករករ៉ែមាសមួយនេះមានឈ្មោះថា ក្រុមហ៊ុន រង ឈីង អ៊ិនដាសស្ទ្រៀល អិនវេសមេន ខូអិលធីឌី។ កន្លងមក ក្រុមហ៊ុននេះធ្លាប់បានធ្វើការសាកល្បងរួចមកហើយ ដោយទទួលបានរ៉ែមាសប្រមាណជាង ២គីឡូក្រាម។

លោក សុផលបានបញ្ជាក់បន្ថែមថា បច្ចុប្បន្ននេះ ក្រុមហ៊ុនបាននិងកំពុងដំណើរការលើការរៀបចំនូវហេដ្ឋារចនាសម្ព័ន្ធរបស់ខ្លួនពាក់ព័ន្ធនឹងខ្សែចង្វាក់ផលិតកម្មសម្រាប់ចម្រាញ់យករ៉ែមាស ព្រមទាំងកំពុងដោះស្រាយផលប៉ះពាល់នៅជុំវិញតំបន់ប្រកបអាជីវកម្មនោះ។ ក្រោយរៀបចំនិងដោះស្រាយរួចរាល់ ក្រុមហ៊ុនអាចនឹងមានជាការប្រកាសជាផ្លូវការដើម្បីសម្ពោធ និងដាក់ដំណើរការការស្លមាសលើកដំបូងរបស់ក្រុមហ៊ុន។

លោកប្រធានមន្ទីរបានអះអាងថា សក្តានុពលធនធានរ៉ែធំបំផុតរបស់ខេត្តមណ្ឌលគិរីគឺ មានតែរ៉ែមាសប៉ុណ្ណោះ ប៉ុន្តែក្រោយមកមានក្រុមហ៊ុនវិនិយោគមកសិក្សាជាបន្តបន្ទាប់ និងបានរកឃើញប្រភពធនធានរ៉ែបន្ថែមទៀត ប៉ុន្តែក្នុងបរិមាណដែលមិនទាន់អាចប្រកបអាជីវកម្មបាន ដូចជា រ៉ែបុកស៊ីត សំណរ ត្បូងថ្ម ជាដើម។

- Video Advertisement -

គម្រោងអភិវឌ្ឍន៍ ថាមពល និងបរិស្ថាន